នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង

នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 06-Jun-2011, 15:49
CMS/CFO: Kauv Keoratanak

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជសដ |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់ | : | ថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១១ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | ខ្មែរ |

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះ: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

## សំណើសុំរបស់សហព្រះរាជអាជ្ញា សុំបន្ថែមពេលវេលា សម្រាប់ដាក់ចម្លើយតបរួម ទៅនឹងសារណាបន្ថែមរបស់ អៀង សារី លើអញ្ញត្រកម្ម អនុលោមតាមវិធាន៨៩ (ការអនុគ្រោះទោស និងការលើកលែងទោស និងគោលការណ៍គ្មានការកាត់ទោសពីរដង ចំពោះបទល្មើសតែមួយ)

---

| **អ្នកដាក់ឯកសារ:** | **អ្នកទទួលឯកសារ:** | |
|---|---|---|
| សហព្រះរាជអាជ្ញា: | អង្គជំនុំជម្រះសាលាដំបូង: | ជនជាប់ចោទ: |
| លោកស្រី ជា លាង | ចៅក្រម និល ណុន, ប្រធាន | នួន ជា |
| លោក Andrew CAYLEY | ចៅក្រម Silvia CARTWRIGHT | អៀង សារី |
| | ចៅក្រម យ៉ា សុខន | អៀង ធីរិទ្ធ |
| | ចៅក្រមJean-Marc LAVERGNE | ខៀវ សំផន |
| | ចៅក្រម យូ អុតារា | |

| សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី: | មេធាវីការពារក្តីជនជាប់ចោទ: |
|---|---|
| ពេជ អង្គ | លោក សុន អរុណ |
| Elisabeth SIMONNEAU FORT | លោក Michiel PESTMAN |
| | លោក Victor Koppe |
| | លោក អាង ឧត្តម |
| | លោក Michael G.KARNAVAS |
| | លោក ផាត់ ពៅស៊ាង |
| | កញ្ញា Diana ELLIS QC |
| | លោក ស សូវ៉ាន |
| | លោក Jacques VERGÈS |

## I. សេចក្តីផ្តើម

១. កាលពីថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១១ សហមេធាវីការពារក្តីឲ្យ អៀង សារី បានដាក់សារណាបន្ថែមចំនួន២ ដោយអនុលោមតាមវិធាន៨៩ នៃវិធានផ្ទៃក្នុងទាក់ទងនឹងបញ្ហា "ការអនុគ្រោះទោស និងការលើកលែងទោស"[1] និងគោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ[2]។ សហព្រះរាជអាជ្ញាសូមស្នើថា ការបរិច្ឆេទសម្រាប់ចម្លើយតបរួមនេះ ទៅនឹងអញ្ញត្រកម្មបឋមរបស់ជនជាប់ចោទគួរត្រូវពន្យារដល់ថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០១១។

## II. មូលហេតុ

២. សហព្រះរាជអាជ្ញាមានបំណងដាក់ចម្លើយតបរួមនេះទៅនឹងសារណាអញ្ញត្រកម្មបន្ថែមពីរនេះ។ ដើម្បីមានពេលវេលាគ្រប់គ្រាន់ក្នុងការបកប្រែភាសាផងនោះ សហព្រះរាជអាជ្ញានឹងចុះហត្ថលេខាលើចម្លើយតបរួម សហព្រះរាជអាជ្ញាស្នើសុំបន្ថែមពេលវេលាសម្រាប់ដាក់ចម្លើយតបរួមរហូតដល់ថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១១ទាក់ទិនទៅនឹងសារណាបន្ថែមរបស់មេធាវី អៀង សារី លើអញ្ញត្រកម្មអនុលោមតាមវិធាន ៨៩ (ការអនុគ្រោះទោស និងការលើកលែងទោស និង គោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ)។

## III. សំណើ

៣. ហេតុដូចនេះ សហព្រះរាជអាជ្ញា សូមស្នើថា សហព្រះរាជអាជ្ញាដាក់ចម្លើយតបរួមជាភាសាខ្មែរ និងភាសាអង់គ្លេសនៅថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១១។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
| --- | --- | --- | --- |
| ថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១១ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | [signature] |
| | **លោក Andrew CAYLEY**<br>សហព្រះរាជអាជ្ញា | | [signature] |

[1] ឯកសារ E51/10, សារណាបន្ថែមរបស់ អៀង សារី ទៅនឹងអញ្ញត្រកម្មតាមវិធាន ៨៩ (ការអនុគ្រោះទោស និងការលើកលែងទោស), ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១១។

[2] ឯកសារ E51/11, សារណាបន្ថែមរបស់ អៀង សារី ទៅនឹងអញ្ញត្រកម្មតាមវិធាន ៨៩ (គោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ), ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១១។